**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៤...០២២...០០៦...ប្រកាសព័ត៌មាន

ថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការដាក់ឱ្យដំណើរការជាផ្លូវការ ខេអេចឃ្យូអរ (KHQR)
## និង
## ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីពី "កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (e-KYC)" រវាងធនាគារជាតិនៃកម្ពុជា និង មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជា សហការជាមួយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា និងភាគីពាក់ព័ន្ធ បានរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ ខេអេចឃ្យូអរ (KHQR) ដើម្បីលើកកម្ពស់ការទូទាត់តាមឃ្យូអរកូត (QR Code) ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ លើកកម្ពស់ការទូទាត់តាមឃ្យូអរកូតឆ្លងគ្រឹះស្ថាន និងជំរុញបរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងផ្ដល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់។

ស្របពេលនឹងការរៀបចំពិធីដាក់ដំណើរការជាផ្លូវការ ខេអេចឃ្យូអរ (KHQR) ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" ក៏បានចុះអនុស្សរណៈយោគយល់ ស្ដីពី "កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល" ដើម្បីរួមចំណែកជំរុញនវានុវត្តន៍ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ លើការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្ន សំដៅគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ តាមរយៈអនុស្សរណៈនេះ ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការគ្នាដើម្បីពិនិត្យលទ្ធភាពប្រើប្រាស់ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) ដែលជាថ្នាលចែករំលែកទិន្នន័យអត្តសញ្ញាណសាធារណជន សម្រាប់យកមកផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាឌីជីថល (e-KYC)។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_OGSSLjXZXvbcATfA